00895023

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28 / 03 / 2013
ម៉ោង (Time/Heure): 09:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E272

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## អង្គជំនុំជម្រះសាលាដំបូង

សាធារណៈ / Public

ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៣

**ជូនចំពោះ៖** ឯកឧត្តម ក្រាញ់ តូនី ប្រធានស្តីទីនៃការិយាល័យរដ្ឋបាល អ.វ.ត.ក

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក /លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ភាគីទាំងអស់នៃសំណុំរឿងលេខ 00២, អនុប្រធានការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក

**កម្មវត្ថុ៖** ស្ថានភាពថវិការបស់ អ.វ.ត.ក

ប្រធានអង្គជំនុំជម្រះសាលាដំបូង ស្នើការិយាល័យរដ្ឋបាលស្វែងរកការបញ្ជាក់ពីភាគីនៃកិច្ចព្រមព្រៀងទាក់ទងនឹងថវិការដើម្បីទ្រទ្រង់ដំណើរការសវនាការរបស់អង្គជំនុំជម្រះសម្រាប់ឆ្នាំ ២០១៣ និង រយៈពេលបីខែ ដំបូងនៃឆ្នាំ ២០១៤។

អង្គជំនុំជម្រះត្រូវការនូវការបញ្ជាក់អំពីស្ថេរភាពនៃថវិការ និងថវិការដែលមានគ្រប់គ្រាន់ ដើម្បីឲ្យអង្គជំនុំជម្រះអាចរៀបចំផែនការការងាររបស់ខ្លួនក្នុងការបញ្ចប់ការជំនុំជម្រះ និងចេញសាលក្រមសំណុំរឿងបច្ចុប្បន្ននេះ។

អង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទនៃការស្តាប់សក្ខីកម្មសាក្សីមួយចំនួនចាប់ពីថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៣ នេះតទៅ ហេតុដូច្នេះអង្គជំនុំជម្រះត្រូវការនូវការបញ្ជាក់ពីបញ្ហាថវិការនេះឲ្យបានត្រឹមថ្ងៃពុធ ទី ០៣ ខែ មេសា ឆ្នាំ ២០១៣។